ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំខែមេសា ឆ្នាំ២០១៤

## I- សភាពការណ៍រួម

ក្នុងខែមេសា ឆ្នាំ២០១៤នេះ ការងារបង្កបង្កើនផលកសិកម្មរដូវប្រាំងឆ្នាំ២០១៣-២០១៤ កសិករបានបញ្ចប់ការដាំដុះស្រូវប្រាំងជាស្ថាពរលើផ្ទៃដីចំនួន ៤៨៤.៦៩៧ហិកតា ស្មើនឹង ១២៦,៣៨% នៃផែនការ ៣៨៣.៥៣០ហិកតា តិចជាងឆ្នាំមុន ១០.៨១០ហិកតា ដោយសារកង្វះខាតទឹកនៅតាមតំបន់ផលិតស្រូវប្រាំងមួយចំនួន ជាពិសេសនៅក្នុងតំបន់អូរតាគីស្រុកបាណន់ ខេត្តបាត់ដំបង ដែលបានថយចុះផ្ទៃដីប្រមាណ២.០០០ហិកតា ព្រោះអាងទឹកកំពីងពួយត្រូវរងការខូចខាត។ ដោយឡែកខេត្តកំពង់ធំ បន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពត ក្រចេះ តាកែវ ពោធិ៍សាត់ និងសៀមរាប អនុវត្តលើសផែនការ។ រីឯលទ្ធផលនិងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗទៀតដែលសម្រេចបានក្នុងខែមេសា ឆ្នាំ២០១៤នេះមានដូចខាងក្រោម៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ ដំណាំស្រូវរដូវប្រាំងឆ្នាំ២០១៣-២០១៤

-ផ្ទៃដីភ្ជួររាស់សរុបចំនួន៥៤៤.៨៦៧ហិកតា តិចជាងឆ្នាំមុនចំនួន២.០៥០ហិកតា ដោយក្នុងនោះភ្ជួររាស់ដោយគ្រឿងយន្ត៤០៥.៧៦៧ហិកតា

-ផ្ទៃដីសាបសរុបចំនួន៤.៨៦២ហិកតា តិចជាងឆ្នាំមុនចំនួន៥៥១ហិកតា

-ផ្ទៃដីសន្ទូងនិងពង្រោះសរុបចំនួន៤៨៤.៦៩៧ហិកតា ស្មើនឹង១២៦,៣៨ភាគរយ នៃផែនការ៣៨៣.៥៣០ហិកតា តិចជាងឆ្នាំមុនចំនួន១០.៨១០ហិកតា

-ការងារប្រមូលផលស្រូវរដូវប្រាំងសម្រេចបានលើផ្ទៃដីចំនួន៤៨៣.៤៤៦ហិកតា ស្មើនឹង៩៩,៧៤% នៃផ្ទៃដីអនុវត្តដោយទទួលបានបរិមាណផលសរុបចំនួន២.១១៨.៧១០តោន និងទិន្នផលជាមធ្យមចំនួន៤,៣៨៣តោនក្នុងមួយហិកតា។

#### ១.២ ដំណាំរួមផ្សំ

ផ្ទៃដីសម្រេចបានចំនួន៨៣.១៧១ហិកតា តិចជាងឆ្នាំមុន៤២.៦០៣ហិកតា ក្នុងនោះមាន៖

-ផ្ទៃដីដាំពោតចំនួន២០.៨៨៨ហិកតា តិចជាងឆ្នាំមុន១៣.៤៣៨ហិកតា

-ផ្ទៃដីដំឡូងឈើចំនួន២៥.៩៧៦ហិកតា តិចជាងឆ្នាំមុន៣.១៣៨ហិកតា

-ផ្ទៃដីដំឡូងជ្វាចំនួន២.៨៣២ហិកតា តិចជាងឆ្នាំមុន២.៦២៤ហិកតា

-ផ្ទៃដីបន្លែគ្រប់មុខចំនួន២២.៧៦៨ហិកតា តិចជាងឆ្នាំមុន១៧.២២១ហិកតា

-ផ្ទៃដីសណ្តែកបាយចំនួន១០.៧០៧ហិកតា តិចជាងឆ្នាំមុន៦.១៨២ហិកតា ។

#### ១.៣ ដំណាំឧស្សាហកម្ម

ផ្ទៃដីសម្រេចបាន១៩.២០៥ហិកតា លើសឆ្នាំមុន៧២៥ហិកតា ក្នុងនោះមាន៖

-ផ្ទៃដីសណ្តែកដីចំនួន២.៧៥៥ហិកតា លើសឆ្នាំមុន៤២៥ហិកតា



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
№ 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia
Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

-ផ្ទៃដីល្ហុងចំនួន១.៩៤៣ហិកតា លើសឆ្នាំមុន៤២២ហិកតា
-ផ្ទៃដីអំពៅចំនួន៥.៩៤៣ហិកតា លើសឆ្នាំមុន៥៤៧ហិកតា
-ផ្ទៃដីក្រចៅចំនួន៤០ហិកតា តិចជាងឆ្នាំមុនចំនួន៩ហិកតា
-ផ្ទៃដីថ្នាំជក់ចំនួន៦.៧៦៣ហិកតា លើសឆ្នាំមុន៨៩០ហិកតា
-ផ្ទៃដីសណ្តែកសៀងចំនួន២៦ហិកតា តិចជាងឆ្នាំមុន២.១២២ហិកតា
-ផ្ទៃដីល្ហុកចំនួន១.០៧៧ហិកតា តិចជាងឆ្នាំមុន៨៥ហិកតា
-ផ្ទៃដីកក់ចំនួន៦៥៧ហិកតា លើសឆ្នាំមុន៣៥៧ហិកតា។

## ២ ផ្នែកកៅស៊ូ

### ២.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីដាំដុះនិងថែទាំ ២០០៣-២០១៣(ហ.ត) | ផលិតផលអនុវត្តបាន ដល់ខែនេះ (តោន) | បញ្ចេញលក់ ដល់ខែនេះ(តោន) |
|---|---|---|---|---|---|
| I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៤០៦,៦០ | ៣៤៤,៣១ | ១៣៦,០៧ | - |
| | សរុប I | ៤០៦,៦០ | ៣៤៤,៣១ | ១៣៦,០៧ | - |
| II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុន សុភក្តិនីកា អ៊ិនវេសមេន គ្រុប | ៩.៣៥៦,៨៨ | ៦.៦៨៩,៤៤ | ៥.២៥៦,៩៦ | ១.៥១៣,៩២ |
| ២ | ក្រុមហ៊ុន ស៊ីហ្វាប់បើយើមីធីត (រតនគីរី) | ៨៦៧,៩៤ | ១.៦២៥,៩០ | ៣៨២,៨១ | - |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ១.២៤១,៨០ | ៨៨៥,០១ | ២៨០,៩៤ | ១០០,០០ |
| ៤ | ក្រុមហ៊ុន ចម្ការកៅស៊ូបឹងកេត | ២.០៥៦,៣២ | ៣.២៦៦,៩២ | ១.២១៣,៣២ | ៨៩១,០០ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣.២៩៥,៥៨ | ៥.២៥៩,០៨ | ១.៤៥៥,៤១ | ៥១២,៨០ |
| ៦ | ក្រុមហ៊ុន ស៊ីហ្សរីសសស (ស្នួល) | ១.៦២៣,២០ | ២.៧៦៣,០១ | ៤៦៣,៩៤ | ២៥៩,០០ |
| ៧ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ពាមជាំង) | ២.១៧៧,០៤ | ១.១៥៩,០០ | ៣៣៣,៤៣ | ១៧៤,០០ |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ២.១៣៥,២៩ | ៣.៦៨៧,៥៣ | ៤៩១,១៦ | ២៩៦,០០ |
| ៩ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (រមាសហែក) | - | ១.៥៧០,៦៣ | - | - |
| ១០ | ក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអិលធីឌី | ២.៨៥២,៧២ | ២.៦១៨,៧៥ | ១.៤៥៣,៥៨ | ២០០.០០ |
| | សរុប II | ២៥.៦០៦,៧៧ | ២៩.៥២៥,២៧ | ១១.៣៣១,៥៥ | ៣.៩៤៦,៧២ |
| III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | | ១៣៥.៨៤៦,០០ | | |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រូសារ | ៥២.៥១៦,០០ | ៨៤.៥០១,០០ | ១២.៥៦២,០០ | ១២.៥៦២,០០ |
| | សរុប III | ៥២.៥១៦,០០ | ២២០.៣៤៧,០០ | ១២.៥៦២,០០ | ១២.៥៦២,០០ |
| | សរុប I+II+III | ៧៨.៥២៩,៣៧ | ២៥០.២១៦,៥៨ | ២៤.០២៩,៦២ | ១៦.៥០៨,៧២ |

### ២.២ ការផ្សព្វផ្សាយនិងបណ្តុះបណ្តាល

-សហការជាមួយក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ (IRRDB) នឹងរៀបចំធ្វើសិក្ខាសាលាស្តីពីការបង្កាត់ពូជនិងការផ្ទេរបច្ចេកវិទ្យាកៅស៊ូ ដែលមានអ្នកចូលរួមពីបណ្តាប្រទេសជាច្រើនដែលជាសមាជិករបស់ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ។

### ២.៣ ការស្រាវជ្រាវអំពីការបង្កាត់ពូជ

-ត្រួតពិនិត្យការប្តូរប្រព័ន្ធមុខចៀរឡូត៍ពិសោធន៍ ស្រង់ទិន្នន័យជំងឺ Oidium និងរៀបចំអត្ថបទសម្រាប់បង្ហាញក្នុងសិក្ខាសាលា។

### ២.៤ ការស្រាវជ្រាវអំពីសរីរវិទ្យានិងរេជីវកម្ម

-តាមដានទិន្នន័យគ្រប់ចម្ការពិសោធន៍ និងរៀបចំវិភាគ LD ចម្ការពិសោធន៍ IRAE 07។

### ២.៥ ការស្រាវជ្រាវ ការដាំដុះ និងការពារ

-តាមដានទិន្នផលកៅស៊ូចម្ការពិសោធន៍ដីលើកូន PB260, PB217

-រៀបចំអត្ថបទស្រាវជ្រាវស្តីពីជំងឺជ្រុះស្លឹកនៅរដូវភ្លៀងនិងជំងឺស្លឹក ករណីស្ប៉ា លើដំណាំកៅស៊ូ។

### ២.៦ ការងារក្នុងមន្ទីរពិសោធន៍យថាប្រភេទ

-ធ្វើតេស្តប្រៀបធៀបមន្ទីរពិសោធន៍ក្នុងស្រុកលើកទី៣៧ ដើម្បីវាយតម្លៃនឹងឈានទៅការទទួលស្គាល់មន្ទីរពិសោធន៍មូលដ្ឋានតាមបណ្តាលក្រុមហ៊ុនចម្ការកៅស៊ូ។

### ២.៧ ការងារនៅស្ថានីយអនុវត្ត

-បំបៅកូនកៅស៊ូលើកទី២បានចំនួន១.៦៤៣ដើម និងជំរះស្មៅវែករងកៅស៊ូដាំឆ្នាំ២០១៣ បានចំនួន១៨,៧៥ហិកតា។

## ៣ ផ្នែកផលិតកម្មនិងបសុព្យាបាល

### ៣.១ ការងារស្ថានីយពិសោធន៍ពូជជ្រូក-គោ

-ជ្រូកសរុបចំនួន៤០៩ក្បាល ក្នុងនោះជ្រូកបាចំនួន១៥ក្បាល ជ្រូកមេចំនួន១០៦ក្បាល និងកូនជ្រូកចំនួន២០០ក្បាល

-គោសរុបចំនួន២០៣ក្បាល ក្នុងនោះគោបាចំនួន៤ក្បាល គោមេប្រាម៉ាន់កាត់ចំនួន៦២ក្បាល គោជំទង់ចំនួន៥៣ក្បាល គោបៅដោះចំនួន៤៦ក្បាល និងគោកំផែងសែនចំនួន៣៨ក្បាល។

### ៣.២ ការចាក់ថ្នាំបង្ការជំងឺឆ្លងសត្វ

-ចាក់ថ្នាំការពារជំងឺឆ្លងលើគោ-ក្របី-ពពែ ជំងឺសារទឹកចំនួន៤.៧៩២ក្បាល និងជំងឺអុតក្តាមចំនួន១៣០ក្បាល

-ចាក់ថ្នាំការពារជំងឺឆ្លងលើសត្វជ្រូក ជំងឺសារទឹកចំនួន១.៣១៨ក្បាល ជំងឺប៉េស្តចំនួន៣.៩០៥ក្បាល ជំងឺសាល់ម៉ូណែឡូសចំនួន២.៧០៧ក្បាល ជំងឺអុតក្តាមចំនួន៩៥ក្បាល ជំងឺអូហ្យេស្គីចំនួន៣០០ក្បាល ជំងឺក្រើលចំនួន៦១ក្បាល ជំងឺជាតិដែកចំនួន១៨៦ក្បាល និងជំងឺផ្លូវដង្ហើមចំនួន៩១ក្បាល

-ចាក់ថ្នាំការពារជំងឺឆ្លងលើបក្សី ជំងឺអុតចំនួន៤.២៩៣ក្បាល ជំងឺញីវកាសចំនួន៦.៣៥០ក្បាល និងជំងឺអាសន្នរោគចំនួន៤.៦០៧ក្បាល។

### ៣.៣ ការងារវិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល

-ចុះអង្កេតស្រាវជ្រាវកន្លែងផ្ទុះជំងឺអុតក្តាម ជំងឺសារទឹក ជំងឺបូសខ្យល់ និងជំងឺប៉េស្តជ្រូក

-រៀបចំធ្វើឲ្យប្រសើរឡើងការងារតាមដានព័ត៌មានសុខភាពសត្វ

-អង្កេតស្រាវជ្រាវ តាមដានឃ្លាំមើល និងយកវត្ថុវិភាគ ស្តីពីជំងឺផ្តាសាយបក្សីនិងជំងឺទូទៅនៅរាជធានី ខេត្ត

-បានពិនិត្យវត្ថុវិភាគសរុបចំនួន៨៩១សំណាក

-ផ្នែកសរីរោគសាស្ត្រសរុបចំនួន៤៧ក្បាល ។

### ៣.៤ ការអនុវត្តវិធានបសុពេទ្យ

-រៀបចំសេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ បានប្រជុំពិភាក្សានៅទីស្តីការគណៈរដ្ឋមន្ត្រីកម្រិតអន្តរក្រសួងចំនួន២លើក

-ទទួលទូរស័ព្ទហៅចូលសរុបចំនួន៦ករណី មកពីតាមបណ្តារាជធានី ខេត្ត វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា និងក្រសួងសុខាភិបាល សាកសួរពីរោគសញ្ញា វិធានការការពារ ការធ្វើជីវសុវត្ថិភាព រាយការណ៍ពីបក្សីឈឺ ងាប់ និងករណីមនុស្សឈឺដោយសារជំងឺផ្តាសាយបក្សី

-តាមដាន ឃ្លាំមើលជាប្រចាំនូវជំងឺផ្តាសាយបក្សីប្រភេទH5N1 និងH7N9 នៅលើទីផ្សាររាជធានី ខេត្តទូទាំងប្រទេស

-ធ្វើការឃាត់ចាប់បទល្មើសពាណិជ្ជកម្មសត្វ ដោយឃាត់ចាប់មាន់ចំនួន២.២៥០ក្បាល ស៊ុតចំនួន១៤៥.៦០០គ្រាប់ និងធ្វើការផាកពិន័យជាទឹកប្រាក់ចំនួន៦.០០០.០០០រៀល

-ចុះធ្វើការបាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងចិញ្ចឹមគោចំនួន២កន្លែង ក្របីចំនួន២កន្លែង ជ្រូកចំនួន១០លើក មាន់ចំនួន១០កន្លែង ទាចំនួន៥៩កន្លែង កន្លែងពិឃាតមាន់ចំនួន២លើក កន្លែងលក់មាន់ចំនួន២លើក ទ្រុងចិញ្ចឹមចំនួន២៥លើក បរិវេណភូមិចំនួន១៣លើក សត្តឃាតដ្ឋានចំនួន២៧លើក និងផ្លូវជាតិចំនួន១លើក

-ធ្វើការទប់ស្កាត់ចលនាបក្សីនិងផលិតផលបក្សីដែលនាំចូលពីប្រទេសជិតខាងដោយខុសច្បាប់ ដោយបានណែនាំប្រជាពលរដ្ឋ និងអាជីវករឲ្យយល់ដឹងពីផលវិបាកដែលបណ្តាលមកពីជំងឺផ្តាសាយបក្សី។

### ៣.៥ ការងារឡជីវឧស្ម័ន

-ចុះផ្សព្វផ្សាយអត្ថប្រយោជន៍ឡជីវឧស្ម័ន

-ផលិតឡជីវឧស្ម័នសរុបចំនួន១៦៧ឡ។

## ៤ ផ្នែករុក្ខាប្រមាញ់

### ៤.១ ការងារចំណូលព្រៃឈើ

-ចំណូលពីផលព្រៃឈើចូលថវិកាជាតិចំនួន២.៨៩៤.៩០៣.០៥១រៀល និងផ្តល់សេវាសាធារណៈចំនួន៩៦.៤៤៥,៧៣ដុល្លារ និង៣.២៨២.៦៤០.៧៥៦រៀល។

### ៤.២ ការងារព្រៃឈើនិងសហគមន៍ព្រៃឈើ

-ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ(LP) ជូនក្រុមហ៊ុននិងអតិថិជន៖ ឈើហ៊ុបមូលសរុបចំនួន១៦.១១៥,២៤៥ម³ កូនឈើចំនួន១៥១.៤២២ដើម អុសចម្រុះចំនួន១៣.៦៤៧ស្ទែរ ជ័រទឹកចំនួន១៦០,៦៤២តោន និងផ្តៅចំនួន២៤តោន។

### ៤.៣ ការងារអភិរក្សធនធានជីវចម្រុះនិងសត្វព្រៃ

-ធ្វើការកត់ត្រាសត្វស្លាបនៅតាមតំបន់អភិរក្សសត្វស្លាបសំខាន់ៗចំនួន៣(បឹងព្រែកល្ពៅ តំបន់អភិរក្សអាងត្រពាំងថ្ម និងតំបន់អភិរក្សសត្វខ្សឹបកំពង់ធំ-សៀមរាប)ដែលមានសត្វស្លាបចំនួនប្រមាណ ៣០៦ប្រភេទ ស្មើនឹង ២៤.៨២៤ក្បាល

-រៀបចំអាហារដ្ឋានក្អាកចំនួន០២លើក នៅតំបន់អភិរក្សជីវចម្រុះសៀមប៉ាងនិងព្រៃការពារព្រះវិហារ ដោយរាប់ឃើញក្អាកសរុបប្រមាណ១១៤ក្បាល

-ការពារសម្បុកក្រយ៉ងចង្កំកស់ចំនួន៣៨ក្បាល រំពេទន្លេចំនួន៦ក្បាល ខ្សឹបចំនួន១ក្បាល រនាលពណ៌ចំនួន២២ក្បាល និងក្អាតចំនួន៩ក្បាល នៅតំបន់សៀមប៉ាងភាគខាងលិច តំបន់ទន្លេមេគង្គលើ អាងត្រពាំងថ្ម និងតំបន់អភិរក្សសត្វខ្សឹប។

### ៤.៤ ការងារអប់រំផ្សព្វផ្សាយនិងបណ្តុះបណ្តាល

-ធ្វើការអប់រំផ្សព្វផ្សាយបានចំនួន២១លើក ស្តីពីប្រកាសការរៀបចំគ្រប់គ្រងតំបន់អភិរក្សសត្វខ្សឹប សកម្មភាពអភិរក្សសត្វក្រៀល និងប្រព័ន្ធអេកូឡូស៊ីរួមនិងការគ្រប់គ្រងធនធានធម្មជាតិដែលមានប្រជាពលរដ្ឋចូលរួមសរុបចំនួន៦៣៨នាក់ ស្ត្រី១៥៨នាក់។

### ៤.៥ កសិដ្ឋានចិញ្ចឹម ការបន្ទាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

-ក្នុងខែមេសា ឆ្នាំ២០១៤នេះ ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹមនិងថែរក្សា៖ សត្វចំណូលថ្មីចំនួន៦៩ក្បាល សត្វកើតថ្មីចំនួន១៥ក្បាល សត្វដោះលែងចំនួន៤៧ក្បាល សត្វស្លាប់ចំនួន១១ក្បាល ព្យាបាលសត្វចំនួន២៦ក្បាល យកសំណាកទៅពិសោធន៍ចំនួន១២ក្បាល ធ្វើឲ្យសន្លប់ចំនួន៣២ក្បាល ទម្លាក់សត្វល្អិតចំនួន២៣ក្បាល វះកាត់សាកសពសត្វចំនួន១០ក្បាល ជុសជុលផ្លូវចំនួន២៨.៨០០ម² សាងសង់សំណង់ផ្សេងៗចំនួន៨ម² ឆ្ការអនាម័យព្រៃចំនួន៤០០ម² ដាំកូនឈើចំនួន៨១៥ដើម និងអប់រំផ្សព្វផ្សាយដល់សិស្សានុសិស្សបានចំនួន៣៣៦នាក់

-ក្រុមហ៊ុនចំនួន០៧ កំពុងចិញ្ចឹមស្វាក្តាមមេ-បាពូជ និងកូនស្វាក្តាមចំនួន៥៦.៥៤៧ក្បាល។

### ៤.៦ គម្រោងអភិរក្សសត្វក្រពើកម្ពុជា អភិរក្សធនធានសេនេទិច និងប្រភេទគ្រាប់ពូជ

-បន្តថែរក្សាកូនក្រពើចំនួន២៦ក្បាលដែលយកពីស្ទឹងអារ៉ែង ឃុំជំនាប់ ស្រុកថ្មបាំង ខេត្តកោះកុង មកថែបំប៉ន

នៅស្ពាក់ការល្បាតអាវែងរបស់រដ្ឋបាលព្រៃឈើក្នុងឃុំថ្មដូនពៅ ស្រុកថ្មបាំង ខេត្តកោះកុង រង់ចាំការដោះលែងចូលបឹងធម្មជាតិនៅចុងឆ្នាំ២០១៤

-បន្តការល្បាតដោយក្រុមល្បាតសហគមន៍ចំនួន២២នាក់ នៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន៤គឺនៅអារ៉ែងក្នុងឃុំថ្មដូនពៅ ស្រុកថ្មបាំង ឆាយរាបក្នុងឃុំដងពែង ស្រុកស្រែអំបិល តំបន់ស្ពានក្រពើក្នុងឃុំតាតៃលើ ស្រុកថ្មបាំង ខេត្តកោះកុង និងអូរសោម ឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់

-តាមដានសត្វក្រពើដែលបានដោះលែង១៥ក្បាល តាមរយៈឧបករណ៍វិទ្យុសំឡេង។

## ៤.៧ ការដាំដើមឈើ

-ស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើចំនួន០៤របស់រដ្ឋបាលព្រៃឈើ ឈូសឆាយដីព្រៃបានចំនួន១៥៥ហិកតា បណ្តុះកូនឈើបានចំនួន១១០.០០០ដើម

-ការដាំឈើដៃគូជាមួយក្រុមហ៊ុន Think Biotech(Cambodia) Co., Ltd បានកាប់ឆ្ការនិងឈូសឆាយសម្អាតដីចំនួន៨៨ហិកតា

-ការដាំឈើដៃគូជាមួយក្រុមហ៊ុន Oji (Cambodia) Plantation បានឈូសឆាយសម្អាតដីចំនួន៣០ហិកតា និងផលិតពូជកូនឈើចំនួន១០០.០០០ដើម

-ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច៤ បានឈូសឆាយដីចំនួន៣.១២៨ហិកតា

-ថ្នាលបណ្តុះកូនឈើរបស់រដ្ឋបាលព្រៃឈើអនុវត្ត៖ បណ្តុះកូនឈើគ្រប់ប្រភេទចំនួន៨៣.៨៥៣ដើម និងចែកចាយកូនឈើបានចំនួន៣.៥៧១ដើម

-សួនបណ្តុះកូនឈើសម្តេចតេជោ ហ៊ុន សែន បានបណ្តុះកូនឈើចំនួន១.៥០០.០០០ដើម

-ដំណាំកសិរុក្ខកម្ម មានឡូត៍ស្រាវជ្រាវប្រព័ន្ធកសិរុក្ខកម្មទំហំ៥ហិកតា ដែលមានទីតាំងនៅក្នុងស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើអូរបឹងរូង ខេត្តកំពង់ធំ។

## ៤.៨ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

### ៤.៨.១ ការងារពាណិជ្ជកម្មនាំចេញនាំចូល

-ពិនិត្យឯកសារស្នើសុំពាក់ព័ន្ធនឹងការនាំចេញឈើកែច្នៃចំនួន០១ក្រុមហ៊ុន

-ផ្តល់អាជ្ញាប័ណ្ណនាំចេញឈើកែច្នៃគ្រប់ប្រភេទជូនក្រុមហ៊ុនចំនួន០១ ដែលមានបរិមាណឈើកែច្នៃចំនួន ៧.៩៩០,១២១ម$^{៣}$។

### ៤.៨.២ ការងារឧស្សាហកម្ម

-ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើនាំចេញជូនក្រុមហ៊ុនចំនួន០២ ស្មើនឹង៨២សន្លឹក ដែលមានបរិមាណឈើចំនួន១២.៩០៣,៩៧៦ម$^{៣}$ ឈើអាកាស្យាកែច្នៃចំនួន៦៣,២០០ម$^{៣}$ និងឈើអាកាស្យាកាត់ជាកង់ៗចំនួន ១៦១,៤៨០ស្តេរ។

## ៤.៩ ការងារនីតិកម្មនិងវិវាទ

-បង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃដោយបញ្ជូនទៅតុលាការសរុបចំនួន ២៤៩ករណី

-ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើបូល-ជ្រុងចំនួន១៥៣,២៧២ម$^{៣}$ ឈើអារចំនួន ៤៣៧,០៧៨ម$^{៣}$ ឈើប្រាក់គ្រញូងចំនួន១៦,៨៦២ម$^{៣}$ និង១.៣៥៤គ.ក្រ និងអនុផលព្រៃឈើ ព្រមទាំងសម្ភារផ្សេងៗមួយចំនួនទៀត ព្រមទាំងដកហូតដីព្រៃឈើចំនួន២២៦,៣០០ហិកតា។

# ៥ ផ្នែកជលផល

## ៥.១ អាជីវកម្មនេសាទ

### ៥.១.១ នេសាទទឹកសាប

-ជាយត្រីក្នុងរដូវនេសាទឆ្នាំ២០១៣-២០១៤ សរុបបានចំនួន១៩.០០០តោន ស្មើ១២៦,៦៧% នៃផែនការ ១៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១០.៥០០តោន

-នេសាទគ្រួសារក្នុងដែននេសាទរដូវឆ្នាំ២០១៤ ក្នុងខែចំនួន២០.០០០តោន សរុបបានចំនួន១៤០.០០០តោន ស្មើ៣៥,៩០% នៃផែនការ៣៩០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៥០.០០០តោន

-នេសាទគ្រួសារតាមវាលស្រែក្នុងរដូវឆ្នាំ២០១៤ ក្នុងខែចំនួន៥.០០០តោន សរុបបានចំនួន៤០.០០០តោន ស្មើ ២២,២២% នៃផែនការ១៨០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើងចំនួន១០.០០០តោន ។

៥.១.២ នេសាទសមុទ្រក្នុងឆ្នាំ២០១៣

-អនុវត្តក្នុងខែចំនួន៩.០០០តោន បានសរុបចំនួន៣៥.៥០០០តោន ស្មើ៣១,៨២% នៃផែនការ១១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១.០០០តោន។

**៥.២ វារីវប្បកម្ម**

-ការចិញ្ចឹមត្រីនិងបង្គា ក្នុងខែចំនួន៨.០០០តោន សរុបបានចំនួន៣០.០០០តោន ស្មើ៣០% នៃផែនការ ១០០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៥.០០០តោន

-ការចិញ្ចឹមក្រពើ ក្នុងខែចំនួន១០.០០០ក្បាល សរុបបានចំនួន៤៥.០០០ក្បាល ស្មើ១៥% នៃផែនការ ៣០០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១២.០០០ក្បាល

-ការភ្ញាស់កូនត្រីពូជ ក្នុងខែចំនួន៧.០០០.០០០កូន សរុបបានចំនួន៣០.០០០.០០០កូន ស្មើ១៦,៦៧% នៃផែនការ១៨០.០០០.០០០កូន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៤.០០០.០០០កូន។

**៥.៣ ការកែច្នៃផលនេសាទ**

-ផលនេសាទទឹកសាបក្នុងរដូវនេសាទ២០១៣-២០១៤ ក្នុងខែចំនួន៥.០០០តោន សរុបបានចំនួន២៥.០០០តោន ស្មើ១៦,៦៧% នៃផែនការ១៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៥.០០០តោន

-ផលនេសាទសមុទ្រក្នុងឆ្នាំ២០១៤ ក្នុងខែចំនួន១.០០០តោន សរុបបានចំនួន៣.៥០០តោន ស្មើ៤៣,៧៥% នៃផែនការ៨.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន២០០តោន

-ការផលិតទឹកត្រី ក្នុងខែចំនួន៧.០០០.០០០លីត្រ សរុបបានចំនួន២៥.០០០.០០០លីត្រ ស្មើ៤១,៦៧% នៃផែនការ៦០.០០០.០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៣.០០០.០០០លីត្រ។

**៥.៤ ការនាំចេញផលនេសាទ**

-ផលនេសាទស្រស់ ក្នុងខែចំនួន៦០០តោន សរុបបានចំនួន៣.៧០០តោន ស្មើ១៨,៥០% នៃផែនការ២០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៣០០តោន

-ផលនេសាទកែច្នៃ ក្នុងខែចំនួន៤០០តោន សរុបបានចំនួន២.១០០តោន ស្មើ២១% នៃផែនការ១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១០០តោន។

**៥.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើស**

-កំណត់ហេតុបទល្មើស សរុបចំនួន៩៨៧ករណី ដែលកើតមាននៅតំបន់ទឹកសាប៩៥៦ករណី និងតំបន់សមុទ្រ ៣១ករណី ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន១៨ករណី គឺតំបន់ទឹកសាបថយចុះ១៩ករណីនិងតំបន់សមុទ្រកើនឡើង១ករណី។ ជំរុញការចុះត្រួតពិនិត្យនិងមានវិធានការដើម្បីលុបបំបាត់បទល្មើសនេសាទតាមគ្រប់រូបភាព។

**៥.៦ ការប្រមូលចំណូល**

-ចំណូលពីវិស័យផលផល ក្នុងខែចំនួន២៧១.៩០០.០០០រៀល សរុបបានចំនួន១.៦៨៨.៩៤០.២៥០រៀល ស្មើ ៥៥,៥១% នៃផែនការ៣.០៤២.៥០០.០០០រៀល ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៦១៧.៤៨៣.៥៥៣រៀល។

## ៦ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

-ចុះរៀបចំ ត្រួតពិនិត្យ ប្រមូលទិន្ន័យ និងវាយតម្លៃដំណើរការការងារពិសោធន៍នៅខេត្តបាត់ដំបង តាកែវ កំពង់ស្ពឺ កំពត និងព្រៃវែង

-ចុះរៀបចំវគ្គបណ្តុះបណ្តាលកសិករ ដែលមានអ្នកចូលរួមចំនួន១៩០នាក់ និងទិវាស្រែបង្ហាញ ដែលមានអ្នកចូលរួមចំនួន៩០នាក់ នៅខេត្តព្រះសីហនុ

-ចុះធ្វើការប្រមូលព័ត៌មានជាមួយឈ្មួញប្រមូលទិញផ្លែស្វាយនៅខេត្តបាត់ដំបង និងខេត្តប៉ៃលិន

-ចុះប្រមូលទិន្នន័យពីការទទួលយកពូជស្រូវទាំង១០ពូជរបស់កសិករ នៅខេត្តកំពង់ឆ្នាំង

-ចុះកំណត់ទីតាំង និងប្រមូលទិន្នន័យការដាំដុះស្រូវដើម្បីផ្ទៀងផ្ទាត់ជាមួយរូបភាពពីផ្កាយរណប និងអនុវត្តការប្រើប្រាស់ឧបករណ៍ Ceptometer នៅខេត្តតាកែវ។

## ៧ ផ្នែករដ្ឋបាល

-ទទួលលិខិតពីក្រសួងនិងស្ថាប័ននានា ក្នុងខែចំនួន៤៣០ច្បាប់ សរុបចំនួន១.៩១៤ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទក្នុងខែចំនួន២៨៩ច្បាប់ សរុបចំនួន១៤១៤ច្បាប់ និងទទួលពីរាជធានី ខេត្ត ក្នុងខែចំនួន៩៨ច្បាប់ សរុបចំនួន៤៤៣ច្បាប់

-បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត ក្នុងខែចំនួន៧០៦ច្បាប់ សរុបចំនួន២.៩៥១ច្បាប់ ប្រកាស សេចក្តីសម្រេច និងសារាចរ ក្នុងខែចំនួន២៣ច្បាប់ សរុបចំនួន១៦៧ច្បាប់ និងចម្លងចែកទៅអង្គភាពក្រោមឱវាទ ក្នុងខែចំនួន៥៧ច្បាប់ សរុបចំនួន៣១០ច្បាប់

-ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងនិងការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិជាដើម ...។ល។

## ៨ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស

ក្របខណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន៦.៧៦០នាក់ នារីចំនួន១.២៨៥នាក់ ស្មើនឹង១៩% ក្នុងនោះ៖

-អង្គភាពថ្នាក់កណ្តាលចំនួន៤.១១៨នាក់ ក្នុងនោះៈនារីចំនួន៧៤៦នាក់ ស្មើនឹង១៨,១១%

-អង្គភាពថ្នាក់រាជធានី ខេត្តចំនួន២.៦៤២នាក់ ក្នុងនោះៈនារីចំនួន៥៣៩នាក់ ស្មើនឹង២០,៤០%

-ប្រកាសលុបឈ្មោះមន្ត្រីចេញពីក្របខណ្ឌចំនួន២០នាក់ ក្នុងនោះបោះបង់ការងារចំនួន៣នាក់ សុំលាឈប់ពីការងារចំនួន៥នាក់ និងមរណភាពចំនួន១២នាក់

-ប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងចំនួន៣នាក់ ផ្ទេរចូលក្រសួងចំនួន៨នាក់ និងផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួងចំនួន១៧នាក់

-រៀបចំធ្វើអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការក្របខណ្ឌថ្មី និងបានរៀបចំធ្វើនិយតកម្មដល់មន្ត្រីរាជការថ្នាក់កណ្តាល និងរាជធានី ខេត្ត

-ពិនិត្យនិងកែតម្រូវលើការប្រែប្រួលនៃស្ថានភាពបុគ្គលិក និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការគ្រប់អង្គភាពថ្នាក់កណ្តាល បញ្ចូលក្នុងតារាងបៀវត្សថ្មីតាមប្រព័ន្ធព័ត៌មានវិទ្យា

-ចេញប្រកាសដាក់មន្ត្រីរាជការឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សចំនួន១៦នាក់។

## ៩ ការងារអប់រំបណ្តុះបណ្តាលកសិកម្ម

### ៩.១ សាលាជាតិកសិកម្មព្រែកលៀប

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៣-២០១៤ សរុបចំនួន១.២៦៣នាក់(ស្រី៤៤៣នាក់)ក្នុងនោះមាននិស្សិតអាហារូបករណ៍ និស្សិតបង់ថ្លៃ និងនិស្សិតបណ្តុះបណ្តាលបន្តថ្ងៃសៅរ៍-អាទិត្យ ដែលកំពុងសិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សាកវប្បកម្ម សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិឧស្សាហកម្ម និងសុរិយោដី។

### ៩.២ សាលាជាតិកសិកម្មកំពង់ចាម

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១២-២០១៣ សរុបមានចំនួន១.៥៥៨នាក់(ស្រី៦០៨នាក់)ក្នុងនោះ៖

-និស្សិតអាហារូបករណ៍សរុប១.២៩៥នាក់(ស្រី៥៣៥នាក់) ក្នុងនោះថ្នាក់បរិញ្ញាវិទ្យាសាស្ត្រកសិកម្ម៩១៣នាក់(ស្រី៣៣៩នាក់) និងថ្នាក់បរិញ្ញារងបច្ចេកទេសកសិកម្ម៣៨២នាក់(ស្រី១៩៦នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

-និស្សិតសិក្សាបង់ថ្លៃ២៦៤នាក់ (ស្រី៧៣នាក់) ថ្នាក់បរិញ្ញាចំនួន២៥២នាក់(ស្រី៧៣នាក់) និងថ្នាក់បរិញ្ញារងចំនួន១២នាក់(ស្រី០នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំ

កៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ។

៩.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

-និស្សិតដែលកំពុងសិក្សាមានចំនួនសរុប៥.៩៧៣នាក់ (ស្រី១.៣៩៦នាក់) ចែកចេញជា១០មហាវិទ្យាល័យគឺ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល បច្ចេកវិទ្យានិងគ្រប់គ្រងកសិកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ កសិឧស្សាហកម្ម រៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញាវិទ្យាសាស្ត្រនិងសាលាក្រោយឧត្តម បណ្តុះបណ្តាលលើកម្មវិធីបរិញ្ញារង បរិញ្ញាបត្របរិញ្ញាជាន់ខ្ពស់ និងថ្នាក់បណ្ឌិតវិទ្យាសាស្ត្រ។

## ១០ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

-ចូលរួមកិច្ចប្រជុំ ជំនួបពិភាក្សាបើកិច្ចសហប្រតិបត្តិការ៖ ពាណិជ្ជកម្មរវាងធុរជនកម្ពុជា-ចិន កិច្ចពិភាក្សាអំពីកម្មវិធីសិក្សាជំនាញកសិកម្មជាមួយសាធារណរដ្ឋបេឡារុស កិច្ចពិភាក្សាអំពីវឌ្ឍនភាពនៃការអនុវត្តផែនការមេ CLV-DTA និងចូលរួមកិច្ចប្រជុំដែលពាក់ព័ន្ធនឹងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ ក្រោមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន និងអាស៊ាន+១ នៅក្រសួងពាណិជ្ជកម្ម កិច្ចប្រជុំពិនិត្យពាក់កណ្តាលអាណត្តិរវាងរាជរដ្ឋាភិបាលកម្ពុជា និងប្រព័ន្ធអង្គការសហប្រជាជាតិ ស្តីពីក្របខ័ណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍នៃប្រព័ន្ធអង្គការសហប្រជាជាតិឆ្នាំ២០១១-២០១៥ ពិភាក្សាការងារជាមួយJICA អំពីគម្រោង 2KR .....។ល។

-បានចាត់បញ្ជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការក្រោមឱវាទក្រសួងទៅចូលរួមប្រជុំ សន្និសីទ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាសរុបចំនួន២៧នាក់ នៅក្នុងប្រទេសចំនួន១៧

-រៀបចំកិច្ចប្រជុំពិសេសក្រុមការងារលើកទី២ ស្តីពីកសិកម្មសរីរាង្គក្នុងតំបន់អាស៊ាន និងកិច្ចប្រជុំលើកទី១០ នៃក្រុមការងារបមាណីអាស៊ាន ស្តីពីផលិតផលសាកវប្បកម្ម និងដំណាំអាហារផ្សេងៗទៀត នៅខេត្តសៀមរាប

-រៀបចំកិច្ចព្រមព្រៀងរវាងអាស៊ាន និងសាធារណរដ្ឋកូរ៉េ អំពីកិច្ចសហប្រតិបត្តិការលើវិស័យព្រៃឈើ

-ទំនាក់ទំនងជាមួយលេខាធិការដ្ឋានអាស៊ានក្នុងកិច្ចសហប្រតិបត្តិការវិស័យកសិកម្ម និងព្រៃឈើក្នុងក្របខណ្ឌអាស៊ាន អាស៊ានបូក៣ និងអាស៊ានដៃគូពិភាក្សា

-រៀបចំឯកសារសហប្រតិបត្តិការជាមួយសហគមន៍អឺរ៉ុប កិច្ចព្រមព្រៀងជាមួយសាធារណរដ្ឋបេឡារុស អង្គការកម្មវិធីអភិវឌ្ឍន៍នៃសហប្រជាជាតិ(UNDP) អង្គការ School Aid Japan ទីភ្នាក់ងារថាមពលអាតូមិកអន្តរជាតិ(IAEA) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុនJICA សាធារណរដ្ឋប៉ូឡូញ ឯកសារស្តីពីកម្មវិធីសកម្មភាពជាតិប្រយុទ្ធប្រឆាំងនឹងឱនភាពដី

-រៀបចំអនុស្សារណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម រវាងកម្ពុជា-ហ្វីលីពីន

-រៀបចំសម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយ ONG ជាដៃគូ ក៏ដូចជាការអន្តរាគមន៍គាំទ្រក្នុងការចុះអនុស្សារណៈយោគយល់គ្នារវាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងការទទួលជួបសវនាការផ្សេងៗរវាងថ្នាក់ដឹកនាំក្រសួងជាមួយដៃគូជាតិ-អន្តរជាតិ។

## III-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០១៣-២០១៤ ត្រូវបានបញ្ចប់ការដាំដុះជាស្ថាពរដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំសន្និបាតបូកសរុបការងារប្រចាំឆ្នាំកាលពីចុងខែមីនា ឆ្នាំ២០១៣ កន្លងមកនេះ និងលើកទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០១៣-២០១៤។ ទន្ទឹមនឹងនេះ នៅតាមផ្នែកផ្សេងៗទៀតដូចជាផ្នែកផលិតកម្មនិងបសុព្យាបាល ដំណាំកសិឧស្សាហកម្ម ព្រៃឈើ ជលផល ផ្នែកសេវាកម្ម ការងារស្រាវជ្រាវផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ការរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៥ ការងារកែទម្រង់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការងារវិនិយោគផ្នែកឯកជនលើវិស័យកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការងារយេនឌ័រ ក៏ដូចជាការអនុវត្តច្បាប់ផ្សេងៗកំពុងត្រូវបានយកចិត្តទុកដាក់ជាប្រចាំ។ ដោយឡែក ក្រសួងបានជំរុញយ៉ាងសកម្មដល់អង្គភាពជំនាញជាសេនាធិការឲ្យចូលរួមកាត់បន្ថយឲ្យបានជាអតិបរមាតាមគ្រប់រូបភាពនៃបទល្មើសផ្សេងៗ (ចលនាសត្វ

ព្រៃឈើ ផលផល សម្ភារកសិកម្ម) ដោយសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរដែនដី និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

ជារួមសមិទ្ធផលដែលសម្រេចបានដូចបានរៀបរាប់ខាងលើនេះ គឺជាផ្លែផ្កានៃកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន ដៃគូអភិវឌ្ឍនានា និងការចូលរួមយ៉ាងសស្រាក់សស្រាំរបស់ប្រជាកសិករយើងផងដែរ ជាពិសេសការត្រៀមលក្ខណៈគ្រប់ជ្រុងជ្រោយដើម្បីជំរុញការងារបង្កបង្កើនផលរដូវវស្សាខាងមុខនេះ។

## V- និសនៅ

-តាមដាននិងអន្តរាគមន៍ចំពោះការផ្ទុះរាលដាល និងការបំផ្លាញដោយសត្វល្អិតជាយថាហេតុចំពោះដំណាំកសិកម្មផ្សេងៗ

-តាមដានចលនានាំចេញស្រូវនិងផ្លែស្រូវ ជាពិសេសតាមច្រកព្រំដែននានា

-បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំផ្សេងទៀត ឬប្រើប្រាស់ពូជស្រូវសមស្របជាមួយនឹងការប្រើប្រាស់ទឹកដោយប្រសិទ្ធភាព ជាពិសេសចំពោះខេត្តដែលមានអរក្សោភាពស្ងៀង (អង្គរ) ដោយជំរុញកសិករឲ្យឆ្លៀតឱកាសដាំដំណាំរួមផ្សំ ដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក លើតំបន់ដីដែលនៅមានសំណើមអាចដាំដុះបាន បន្ទាប់ពីប្រមូលផលស្រូវវស្សា ដើម្បីបានផលកម្រៃបន្ថែមដល់សេដ្ឋកិច្ចគ្រួសារ

-បន្តរបស់ផ្សព្វផ្សាយ និងជួយដល់ប្រជាកសិករក្នុងការតម្កល់និងរក្សាទឹកសម្រាប់ប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃនិងការបង្កបង្កើនផល

-បន្តអប់រំផ្សព្វផ្សាយដល់ប្រជាកសិករដែលធ្វើស្រូវចម្ការឱ្យប្តូរពូជស្រូវដើម្បីបង្កើនទិន្នផលនិងយកចិត្តទុកដាក់ជំរុញការប្រុងប្រយ័ត្នបង្ការភ្លើងឆេះស្រូវជាយថាហេតុក្នុងរដូវប្រាំងនេះ

-ពិនិត្យ និងពង្រឹងឡើងវិញនូវមធ្យោបាយនិងសម្ភារផ្សេងៗដើម្បីត្រៀមលក្ខណៈជួយអន្តរាគមន៍មានដូចជា៖ ស្រូវពូជនិងពូជបន្លែ មធ្យោបាយនានាសម្រាប់អន្តរាគមន៍ដល់គ្រោះរាំងស្ងួត (អន្តរាគមន៍បូមបាច) និងមធ្យោបាយ សម្ភារនានាដើម្បីទប់ទល់ជំងឺសត្វនិងជំងឺឬសគូចម្រែងបំផ្លាញដំណាំ។ល។

-ការបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ក៏ដូចជាការរៀបចំគំរូការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិពាណិជ្ជកម្ម

-អង្កេតឲ្យទៅស្ថានភាពជំងឺគ្រប់ឡត់ពិសោធន៍ក្នុងកៅស៊ូនិងត្រួតពិនិត្យជំងឺកៅស៊ូ

-ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

-រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី ខេត្ត

-ថែទាំសុខភាព តាមដានជំងឺសត្វ និងមានវិធានការអន្តរាគមន៍តាមការចាំបាច់

-ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យនៅកន្លែងផ្ទុះជំងឺនិងកន្លែងដែលមានការឆ្លងរាលដាលជំងឺផ្តាសាយបក្សីនិងជំងឺផ្តាសាយ H5N1

-ពង្រឹងទប់ស្កាត់ចរាចរណ៍សត្វនិងផលិតផលសត្វតាមទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ

-ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកគ្រុនចៀកខៀវ ប៉េស្ត និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

-ចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត

-ជំរុញដាក់ឲ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការនិងតាមការពិន័យអន្តរការណ៍

-បន្តតាមដានត្រួតពិនិត្យនិងវាយតម្លៃប្រសិទ្ធភាពនៃកម្មវិធី ដោយលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ និងការពង្រីកសហគមន៍ព្រៃឈើឲ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីចំនួន១០០កន្លែងបន្ថែមទៀត

-បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើនិងភាគីពាក់ព័ន្ធ

-បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើសត្វព្រៃតាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

-កំណត់តំបន់ព្រៃឈើរេចរឹលឲ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឲ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

-បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឲ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់

-រៀបចំសេចក្តីណែនាំនិងដាក់ឲ្យប្រើប្រាស់សៀវភៅកត់ត្រាឈើចេញចូលតាមរោងសន្និធិផល អនុផលព្រៃឈើ

-ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងវិស័យជលផល

-រៀបចំបោះបង្គោលបេតុងចំនួន១៥០បង្គោលនិងសាងសង់ស្លាកការព្យាតចំនួន១៦កន្លែងនៅកន្លែងអភិរក្សជលផល

-បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ

-រៀបចំនិងអនុវត្តវិធានការការពារដែននេសាទនិងធនធានជលផល

-បន្តស្រាវជ្រាវដកហូតនិងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ

-រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ

-បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឲ្យបានគ្រប់ឃុំ

-ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៤ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទជាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី បង្គា ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការកែច្នៃផលនេសាទ (ការកែច្នៃផលនេសាទទឹកសាប ការកែច្នៃផលនេសាទសមុទ្រ ការផលិតទឹកត្រី) ការនាំចេញផលនេសាទនិងការបង្កើនផលចំណូលថវិកាជាតិ

-បន្តរៀបចំទិវាមច្ឆជាតិ១កក្កដានិងរុក្ខទិវា៩កក្កដាជារៀងរាល់ឆ្នាំ សំដៅបង្កើនការយល់ដឹងអំពីសារៈសំខាន់នៃធនធានជលផលនិងព្រៃឈើ

-ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២

-បន្តជំរុញការត្រួតពិនិត្យ និងតាមដានការបង្ក្រាបបទល្មើសនេសាទ

-ទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ស្តីពីថ្នាំកសិកម្មនិងជីកសិកម្ម

-ពង្រឹងការងារបញ្ជិកាគណនេយ្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្មរាជធានី-ខេត្ត ក៏ដូចជាការត្រៀមលក្ខណៈរួចរាល់ក្នុងការអនុវត្តថវិកាតាមកម្មវិធីនៅឆ្នាំ២០១៥

-បន្តចុះពិនិត្យផ្ទាល់ដល់ទីតាំងរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឲ្យបានច្បាស់លាស់និងការប្រមូលចំណូលបង់ចូលថវិកាជាតិ

-បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារៈនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមវិស័យទាំងក្នុងនិងក្រៅប្រទេសឲ្យបានទូលំទូលាយ

-ត្រៀមរៀបចំកិច្ចប្រជុំលើកទី៣៥ នៃរដ្ឋមន្ត្រីកសិកម្មនិងព្រៃឈើអាស៊ាន ព្រមទាំងកិច្ចប្រជុំអមមួយចំនួនទៀត និងធ្វើជាម្ចាស់ផ្ទះសម្រាប់កិច្ចប្រជុំស្តីពីវិស័យកសិកម្មនិងព្រៃឈើអាស៊ានឆ្នាំ២០១៤ ធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំលើកទី ១០ ស្តីពីបណ្តាញត្រួតពិនិត្យអាស៊ានលើចំណីអាហារដែលមានប្រភពពីផលិតផលបម្រែបម្រួលហ្សែន និងត្រៀមចូលរួមកិច្ចប្រជុំកំពូល ACMECS លើកទី៥ និងCLMV លើកទី៦

-បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវនិងកសាងគោលការណ៍លិខិតបទដ្ឋានណែនាំជាសារាចរ សេចក្តីណែនាំអំពីការងារគ្រប់គ្រងមន្ត្រីរាជការ និងរៀបចំបែបបទការអនុវត្តជាក់ស្តែងក្នុងការគ្រប់គ្រងធនធានមនុស្សឲ្យល្អប្រសើរតាមប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា ដោយចងក្រងតាមកម្រិតសញ្ញាបត្រ មុខជំនាញ និងតាមមុខតំណែង

-ពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សឲ្យបានសមស្របទៅតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការនៃ

ព្រះរាជាណាចក្រកម្ពុជា

-បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ច្បាប់ស្តីពីសហគមន៍កសិកម្ម ដើម្បីធានាដល់ប្រសិទ្ធភាពពេញលេញក្នុងការអនុវត្ត

-បន្តរៀបចំច្បាប់ផ្សេងៗទៀតតាមផ្នែកនីមួយៗតាមការចាំបាច់ ដូចជាច្បាប់ស្តីពីកៅស៊ូ ច្បាប់ស្តីពីការគ្រប់គ្រងដីកសិកម្ម ច្បាប់ស្តីពីសត្វព្រៃនិងជីវចម្រុះ ច្បាប់ស្តីពីគុណភាព និងសុវត្ថិភាពផលិតផលកសិកម្មដើម្បីធានាដល់ដំណើរការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទឲ្យបានសបស្រប៕

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**